**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខៈ ៧២០២ មស.សាលាន

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៤៩៧អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

ដើម្បីជានាឱ្យការអនុវត្តអនុក្រឹត្យនេះប្រកបដោយប្រសិទ្ធភាព ក្រសួងមុខងារសាធារណៈ ដាក់ចេញនូវសេចក្តីណែនាំស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិដូចខាងក្រោម៖

### I. គោលការណ៍

រាល់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាពការងារ ពិគ្រោះយោបល់ តម្លាភាព គណនេយ្យភាព សមធម៌ យុត្តិធម៌ អព្យាក្រឹតភាពមន្ត្រីរាជការ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ដើម្បីជានាដល់ការអនុវត្តតាមគោលការណ៍ខាងលើ រាល់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិត្រូវអនុវត្តដូចខាងក្រោម៖

- ការតែងតាំងមន្ត្រី ត្រូវធ្វើឡើងឱ្យបានសមស្របទៅតាមចំនួនមុខតំណែងទំនេរ បេសកកម្ម ទំហំការងារ សំណូមពរ និងភារកិច្ចជាក់ស្តែង ដោយមិនត្រូវតែងតាំងឱ្យលើសចំនួនមុខតំណែងដែលបានកំណត់នៅក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬក្នុងរចនាសម្ព័ន្ធមន្ទីរ អង្គភាព ការិយាល័យជំនាញនីមួយៗឡើយ
- ការផ្លាស់ប្តូរមន្ត្រី ត្រូវអនុវត្តឱ្យបានសមស្របទៅតាមគោលការណ៍អាណត្តិនិងមូលហេតុជាក់លាក់
- ការបញ្ចប់ភារកិច្ច ត្រូវបានអនុវត្តក្នុងករណីដូចជា ការបាត់បង់សម្បទាវិជ្ជាជីវៈ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌដើម ការទទួលទណ្ឌកម្មខាងវិន័យដោយសារប្រព្រឹត្តកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជានិងអនុក្រឹត្យលេខ១០អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិលជាដើម។



អាសយដ្ឋានៈ ផ្លូវលំលេខ៧ (កែងផ្លូវសឡាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

- កិច្ចប្រជុំរបស់គណៈអភិបាលនិងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដែលពិភាក្សានិង/ឬអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលត្រូវធ្វើឡើងជាសម្ងាត់
- ក្រុមប្រឹក្សា ត្រូវធ្វើការអនុម័តលើសំណើសុំតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងណាមួយតាមរយៈការបោះឆ្នោតជាសម្ងាត់
- រាល់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល ចាំបាច់ត្រូវមានកិច្ចប្រជុំពិនិត្យវាយតម្លៃឱ្យបានច្បាស់លាស់ស្របតាមគោលការណ៍ និង នីតិវិធីដែលបានកំណត់នៅក្នុងសេចក្តីណែនាំនេះ
- រាល់ការតែងតាំង ត្រូវផ្តោតការយកចិត្តទុកដាក់និងផ្តល់អាទិភាពដល់មន្ត្រីរាជការស៊ីវិលជាស្ត្រីឬជាជនពិការដែលកំពុងបម្រើការងារនៅថ្នាក់ក្រោមជាតិ
- ការតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬក្នុងរចនាសម្ព័ន្ធមន្ទីរ អង្គភាព ការិយាល័យជំនាញរបស់ក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តចំពោះតែមន្ត្រីរាជការស៊ីវិលស្ថិតក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននោះតែប៉ុណ្ណោះ។ ក្នុងករណីចាំបាច់ ការតែងតាំងអាចជ្រើសរើសយកពីមន្ត្រីក្របខ័ណ្ឌផ្សេងបាន ក៏ប៉ុន្តែត្រូវមានការផ្ទេរក្របខ័ណ្ឌជាមុនសិនតាមនីតិវិធីជាធរមាន ហាមឃាត់ដាច់ខាតការតែងតាំងមុខតំណែងក្នុងមុខងារសាធារណៈនូវមន្ត្រីកម្មសិក្សាសាកល្បងដែលពុំទាន់ត្រូវបានសម្រេចតាំងស៊ប់ក្នុងក្របខ័ណ្ឌឬអ្នកដែលគ្មានឈ្មោះក្នុងក្របខ័ណ្ឌមុខងារសាធារណៈ
- ការតែងតាំងមន្ត្រីឱ្យកាន់មុខតំណែងណាមួយត្រូវផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ និង ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងសេចក្តីណែនាំនេះ
- ក្នុងករណីដែលមិនអាចជ្រើសរើសមន្ត្រីដែលមានឧបនិស្ស័យសមស្របទៅនឹងមុខតំណែងណាមួយ អាចប្រគល់ភារកិច្ចជូនមន្ត្រីដែលមានលក្ខណសម្បត្តិសមស្របបាន។ ក្នុងករណីនេះសាមីខ្លួនមានសិទ្ធិទទួលបានប្រាក់បំណាច់មុខងារតាមមុខតំណែងនោះនិងអាចត្រូវបានបន្តការឡើងថ្នាក់ក្នុងឋានន្តរស័ក្តិ និង ការឡើងឋានន្តរស័ក្តិក្នុងប្រភេទក្របខ័ណ្ឌរបស់ខ្លួនដែលមានមុនពេលប្រគល់ភារកិច្ចក្នុងមុខតំណែងថ្មី។ ចំពោះប្រភេទក្របខ័ណ្ឌរបស់សាមីខ្លួនមិនត្រូវបានកែសម្រួលតាមមុខតំណែងថ្មីនេះឡើយ
- មន្ត្រីក្នុងឋានន្តរស័ក្តិ ឬ ថ្នាក់ណាមួយមិនអាចត្រូវបានចាត់ឱ្យទៅធ្វើការក្រោមបង្គាប់មន្ត្រីដែលមានឋានន្តរស័ក្តិឬថ្នាក់ទាបជាងខ្លួនឡើយ លើកលែងតែក្នុងករណីចាំបាច់ហើយសាមីខ្លួនដែលមានឋានន្តរស័ក្តិឬថ្នាក់ធំជាងនោះយល់ព្រម។

II. **នីតិវិធី**

ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រី ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

### គ. ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រីបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

#### គ.១. មុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត៖

នីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

<u>ជំហានទី១</u>៖

នាយករដ្ឋបាលសាលារាជធានី ខេត្ត ដោយមានទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលារាជធានី ខេត្តជាសេនាធិការ ត្រូវរៀបចំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំទីចាត់ការឬអង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សានិងផ្តល់ជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយដូចបានកំណត់ខាងលើ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ក្នុងការកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំង ជាបឋមត្រូវផ្តោតទៅលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ហើយកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្តសាមី។ ការជ្រើសរើសបេក្ខជនសម្រាប់ការស្នើតែងតាំងមុខតំណែងណាមួយ គួរជ្រើសរើសឲ្យបានយ៉ាងតិច០២រូប ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ នាយករដ្ឋបាល ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងសម្រេចពីគណៈអភិបាលរបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធនានាដូចមានកំណត់នៅក្នុងចំណុច III នៃសេចក្តីណែនាំនេះ។

<u>ជំហានទី២</u>៖

បន្ទាប់ពីទទួលបានសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នា ដើម្បីកំណត់ជ្រើសរើសយកបេក្ខជន០១រូប ដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របជាងគេសម្រាប់ស្នើសុំតែងតាំង ឬ ត្រូវពិនិត្យនិងពិភាក្សាមានការឯកភាពគ្នាលើមូលហេតុដែលតម្រូវឲ្យមានការស្នើសុំផ្លាស់ប្តូរ ឬ បញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយនោះ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុនិងរបាយការណ៍ច្បាស់លាស់។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ អភិបាលដោយមាននាយករដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុច III នៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របសម្រាប់មុខតំណែងដែលត្រូវស្នើសុំតែងតាំង អភិបាលរាជធានី ខេត្ត បន្ទាប់ពីមានការឯកភាពពីក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ជំហានទី៣៖

ក្រោយពីបានទទួលបានសំណើពីអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និង អនុម័តលើសំណើខាងលើតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

ជំហានទី៤៖

បន្ទាប់ពីបានទទួលការអនុម័តយល់ព្រមពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងដែលបានស្នើសុំឬ/និងចាត់វិធានការចាំបាច់នានាបន្ថែមទៀតផ្អែកទៅតាមសេចក្តីសម្រេចនិងយោបល់ណែនាំរបស់ក្រុមប្រឹក្សា។

ជំហានទី៥ ៖

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះមកក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្ស និង ការងារក្របខ័ណ្ឌ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**ក.២. មន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុនៃសាលារាជធានី ខេត្ត**

ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

ជំហានទី១ ៖

នាយករដ្ឋបាលសាលារាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំជាមួយនាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលារាជធានី ខេត្ត ដើម្បីពិភាក្សានិងផ្តួងជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ក្នុងការកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំង ជាបឋមត្រូវផ្តោតទៅលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ហើយកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្តសាមី។ ការជ្រើសរើសបេក្ខជនសម្រាប់ការស្នើតែងតាំងមុខតំណែងខាងលើ គួរជ្រើសរើសឲ្យបានយ៉ាងតិច០២រូប ដោយផ្អែកលើលក្ខណសម្បត្តិ និង ឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ នាយករដ្ឋបាល ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងសម្រេចពីគណៈអភិបាលរបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ជំហានទី២ ៖

បន្ទាប់ពីទទួលបានសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នា ដើម្បីកំណត់ជ្រើសរើសយកបេក្ខជន០១រូបដែលមានលក្ខណសម្បត្តិ និង ឧបនិស្ស័យសមស្របជាងគេ សម្រាប់ធ្វើការស្នើសុំតែងតាំងឬត្រូវពិនិត្យ និង ពិភាក្សាមានការឯកភាពគ្នាលើមូលហេតុដែលតម្រូវឲ្យមានការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុនិងរបាយការណ៍ច្បាស់លាស់។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ អភិបាលរាជធានី ខេត្ត ដោយមាននាយករដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនដែលមានលក្ខណសម្បត្តិនិងឧប្បនិស្ស័យសមស្របសម្រាប់មុខតំណែងដែលត្រូវស្នើសុំតែងតាំង អភិបាលរាជធានី ខេត្ត បន្ទាប់ពីមានការឯកភាពពីក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើសុំផ្ទេរមន្ត្រីមកពីក្រសួងមហាផ្ទៃ ឬពីសាលារាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ជំហានទី៣៖

ក្រោយពីបានទទួលបានសំណើពីអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សា ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និង អនុម័តលើសំណើខាងលើតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

ជំហានទី៤៖

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើនេះមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និង ពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការឯកភាពលើសំណើនេះ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ជំហានទី៥៖

បន្ទាប់ពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។

ក្នុងករណីដែលពុំមានការឯកភាពលើសំណើរបស់អភិបាលរាជធានី ខេត្ត រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជូនដំណឹងទៅអភិបាលរាជធានី ខេត្ត ដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះនិងស្នើឲ្យអភិបាលរាជធានី ខេត្ត លើកសំណើបេក្ខជនថ្មីសម្រាប់ធ្វើការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ។

ក្នុងការលើកសំណើបេក្ខជនថ្មីសម្រាប់ធ្វើការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ ត្រូវអនុវត្តតាមជំហានទី១ដល់ជំហានទី៥ឡើងវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ។ ក្នុងករណីស៊ើបអង្កេតរកឃើញថាសំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្តអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ។

ជំហានទី៦៖

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះមកក្រសួងមហាផ្ទៃ និង ក្រសួងមុខងារសាធារណៈក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្សនិងការងារក្របខ័ណ្ឌ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**ក.៣. មុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ**

ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

ជំហានទី១៖

នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌជាសេនាធិការ ត្រូវរៀបចំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំការិយាល័យ ឬ អង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សានិងផ្តល់ជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយដូចបានកំណត់ខាងលើ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើសុំតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ក្នុងការកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំង ជាបឋមត្រូវផ្តោតទៅលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ហើយកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសាមី។ ការជ្រើសរើសបេក្ខជនសម្រាប់ការស្នើតែងតាំងមុខតំណែងណាមួយ គួរជ្រើសរើសឲ្យបានយ៉ាងតិច០២រូប ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ នាយករដ្ឋបាល ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងសម្រេចពីគណៈអភិបាលរបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ជំហានទី២៖

បន្ទាប់ពីទទួលបានសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នា ដើម្បីកំណត់ជ្រើសរើសយកបេក្ខជន០១រូប ដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្រប

ជាងគេសម្រាប់ធ្វើការស្នើសុំតែងតាំងឬត្រូវពិនិត្យនិងពិភាក្សាឱ្យមានការឯកភាពគ្នាលើមូលហេតុដែលតម្រូវឲ្យមានការស្នើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុនិងរបាយការណ៍ច្បាស់លាស់។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ អភិបាលក្រុង ស្រុក ខណ្ឌដោយមាននាយករដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធនានាដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណសម្បត្តិ និង ឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

<u>ជំហានទី៣៖</u>

ក្រោយពីបានទទួលបានសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យនិងអនុម័តលើសំណើខាងលើតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

<u>ជំហានទី៤៖</u>

បន្ទាប់ពីបានទទួលការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនទៅអភិបាលរាជធានី ខេត្តសាមី ដើម្បីចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងដែលបានស្នើសុំឬចាត់វិធានការចាំបាច់នានាបន្ថែមទៀតផ្អែកទៅតាមសេចក្តីសម្រេច និង យោបល់ណែនាំរបស់ក្រុមប្រឹក្សា ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

<u>ជំហានទី៥៖</u>

បន្ទាប់ពីបានទទួលសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិនិត្យទៅលើភាពសមស្របនៃលក្ខណសម្បត្តិនិងឧបនិស្ស័យរបស់បេក្ខជនដែលស្នើតែងតាំងឬភាពសមហេតុផលនៃការស្នើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីដែលបានស្នើឡើងដោយអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ អំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

<u>ជំហានទី៦៖</u>

ក្នុងករណីដែលការពិនិត្យឃើញថា បេក្ខជនដែលស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនោះមានលក្ខណៈសមស្រប អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខ

តំណែងដែលបានស្នើសុំនោះយ៉ាងយូរក្នុងរយៈពេល១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីបេក្ខជនដែលការស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណសម្បត្តិនិងឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របមកជំនួស។ ចំពោះករណីនេះ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការជ្រើសរើសបេក្ខជនថ្មី ដោយត្រូវអនុវត្តតាមជំហានទី១ដល់ជំហានទី៤ខាងលើឡើងវិញ។

<u>ជំហានទី៧៖</u>

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការទៅក្រសួងមហាផ្ទៃនិងក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្សនិងការងារក្របខ័ណ្ឌ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**ក.៩. មុខតំណែងប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ**

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

<u>ជំហានទី១៖</u>

នាយកនិងនាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំពិភាក្សានិងផ្តល់ជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ក្នុងការកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំង ជាបឋមត្រូវផ្តោតទៅលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ ហើយកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសាមី។ ការជ្រើសរើសបេក្ខជនសម្រាប់ការស្នើតែងតាំងមុខតំណែងខាងលើ គួរជ្រើសរើសឲ្យបានយ៉ាងតិច០២រូប ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ នាយករដ្ឋបាល ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងសម្រេចពីគណៈអភិបាលរបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

<u>ជំហានទី២៖</u>

បន្ទាប់ពីទទួលបានសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីធ្វើការពិនិត្យនិងពិភាក្សាឲ្យមានការ

ឯកភាពគ្នា ដើម្បីកំណត់ជ្រើសរើសយកបេក្ខជន០១រូបដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្រប ជាងគេសម្រាប់ធ្វើការស្នើសុំតែងតាំង ឬ ត្រូវពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នាលើមូលហេតុដែលនាំឲ្យមានការស្នើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុនិងរបាយការណ៍ច្បាស់លាស់។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមាននាយករដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីជ្រើសរើសបេក្ខជនដែលមានលក្ខណៈសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ជំហានទី៣៖

ក្រោយពីបានទទួលបានសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សា ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យនិងអនុម័តលើសំណើខាងលើតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

ជំហានទី៤៖

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនមកអភិបាលរាជធានី ខេត្តសាមី ដើម្បីលើកសំណើនេះជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យនិងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការផ្តល់ការឯកភាពលើសំណើនេះ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ជំហានទី៥៖

បន្ទាប់ពីបានទទួលសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិនិត្យទៅលើភាពសមស្របនៃលក្ខណសម្បត្តិនិងឧបនិស្ស័យរបស់បេក្ខជនដែលស្នើតែងតាំង ឬ ភាពសមហេតុផលនៃការស្នើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីដែលបានស្នើឡើងដោយអភិបាលក្រុង ស្រុក ខណ្ឌ។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីគណៈអភិបាលរាជធានី ខេត្តឯកភាពលើសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យនិងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ការឯកភាពលើសំណើនេះ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុច IIIនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលបេក្ខជនស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណសម្បត្តិ និង ឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របមកជំនួស។ ចំពោះករណីនេះ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការជ្រើសរើសបេក្ខជនថ្មី ដោយត្រូវអនុវត្តតាមជំហានទី១ដល់ជំហានទី៤ខាងលើ។

ជំហានទី៦៖

បន្ទាប់ពីទទួលបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងនេះ។

ក្នុងករណីដែលពុំមានការឯកភាព រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងទៅអភិបាលរាជធានី ខេត្ត ដោយបញ្ជាក់អំពីហេតុផលនៃការពុំឯកភាពនេះ និង/ឬ ស្នើឲ្យអភិបាលរាជធានី ខេត្តសាមីពិភាក្សាជាមួយអភិបាលក្រុង ស្រុក ខណ្ឌសាមីក្នុងការលើកសំណើបេក្ខជនថ្មីសម្រាប់ការតែងតាំងមន្ត្រីក្នុងមុខតំណែងនេះ។

ជំហានទី៧៖

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការទៅក្រសួងមហាផ្ទៃនិងក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្សនិងការងារក្របខ័ណ្ឌ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**ខ.ការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រីដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យរបស់ក្រសួង ស្ថាប័ននានានៅថ្នាក់ក្រោមជាតិ**

**ខ.១.មុខតំណែងប្រធានមន្ទីរឬប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត**

ក្នុងការតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងប្រធានមន្ទីរឬប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត អភិបាលរាជធានី ខេត្ត មានសិទ្ធិលើកសំណើមករដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនីមួយៗ។

ក្នុងការលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើនេះ ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

ជំហានទី១៖

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីពិភាក្សានិងផ្តល់ជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើនេះ។

ក្នុងករណីចាំបាច់ អភិបាល អាចអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗឲ្យចូលរួម ដើម្បីផ្តល់យោបល់ក្នុងកិច្ចប្រជុំនេះ។

កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ចំពោះការជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ជាបឋមត្រូវផ្ដោតលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗ ហើយដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្តសាមី ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីណែនាំនេះ។

ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេងឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

<u>ជំហានទី២៖</u>

បន្ទាប់ពីមានការឯកភាពពីគណៈអភិបាលរបស់ខ្លួនអំពីបេក្ខជនដែលត្រូវស្នើតែងតាំង ឬ មូលហេតុដែលត្រូវស្នើផ្លាស់ប្ដូរឬស្នើបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើ អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះជូនទៅប្រធានក្រុមប្រឹក្សា ដើម្បីសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្ដីណែនាំនេះ។

<u>ជំហានទី៣៖</u>

ក្រោយពីទទួលបានសំណើពីអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យនិងអនុម័តតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្ដីណែនាំនេះ។

<u>ជំហានទី៤៖</u>

បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ត្រូវលើកសំណើជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យនិងសម្រេចលើការតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីដែលបានស្នើឡើងនេះ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្ដីណែនាំនេះ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្ដូរឬបញ្ចប់ភារកិច្ចមន្ត្រីដែលបានស្នើសុំនេះ។

ក្នុងករណីដែលស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ត្រូវធ្វើលិខិតជម្រាបជូនអភិបាលរាជធានី ខេត្ត អំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្ដូរឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ រដ្ឋមន្ត្រីឬប្រធានស្ថាប័ននោះត្រូវចេញប្រកាសផ្លាស់ប្ដូរឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនីមួយៗត្រូវសម្រេចអំពីការយល់ព្រមឬមិនយល់ព្រម ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការងារ បន្ទាប់ពីទទួលបានសំណើពីអភិបាលរាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខជនដែលស្នើតែងតាំង ឬផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ត្រូវធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនិងអភិបាលរាជធានី ខេត្ត និង/ឬ ត្រូវធ្វើសេចក្ដីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យនិងសម្រេច។

**៩.២.មុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរឬក្រោមប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត**

ការតែងតាំង ឬការផ្លាស់ប្ដូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងចាប់ពីថ្នាក់ក្រោមប្រធានមន្ទីរឬក្រោមប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលនៅថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

ជំហានទី១៖

ប្រធានមន្ទីរ អង្គភាពសាមី ត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងថ្នាក់ដឹកនាំមន្ទីរ អង្គភាពសាមីរបស់ខ្លួន ដើម្បីពិភាក្សានិងផ្តួងជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើនេះ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់ដែលនាំឲ្យមានការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។

ក្នុងការកំណត់ជ្រើសរើសបេក្ខជនសម្រាប់ស្នើតែងតាំង ជាបឋមត្រូវផ្តោតទៅលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមី ហើយកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្តសាមី។ ការជ្រើសរើសបេក្ខជនសម្រាប់ការស្នើតែងតាំងមុខតំណែងខាងលើគួរជ្រើសរើសឲ្យបានយ៉ាងតិច០២រូប ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ ប្រធានមន្ទីរ អង្គភាពសាមី ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងសម្រេចពីគណៈអភិបាលរាជធានី ខេត្តសាមី ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ជំហានទី២៖

បន្ទាប់ពីទទួលបានសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយមានការចូលរួមពីប្រធានមន្ទីរឬអង្គភាពសាមីដើម្បីធ្វើការពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងការកំណត់ជ្រើសរើសយកបេក្ខជន០១រូបដែលមានលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របជាងគេសម្រាប់ធ្វើការស្នើសុំតែងតាំង ឬ ត្រូវពិនិត្យនិងពិភាក្សាឱ្យមានការឯកភាពគ្នាលើមូលហេតុដែលតម្រូវឲ្យមានការស្នើសុំផ្លាស់ប្តូរ ឬ បញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងណាមួយខាងលើ។ កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុនិងរបាយការណ៍ច្បាស់លាស់។

បន្ទាប់ពីបានឯកភាពក្នុងកិច្ចប្រជុំខាងលើ អភិបាលរាជធានី ខេត្ត ដោយមាននាយករដ្ឋបាលជាសេនាធិការ ត្រូវរៀបចំបែបបទស្នើសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្រប អភិបាលរាជធានី ខេត្ត រួមជាមួយនឹងប្រធានមន្ទីរ អង្គភាពសាមីដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារាជធានី ខេត្តសាមី អាចស្នើសុំយោបល់ពីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដើម្បីផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័នសាមី ឬពីមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នសាមីនៅរាជធានី ខេត្តផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សា

របស់ខ្លួន ត្រូវធ្វើលិខិតជម្រាបជូនប្រធានមន្ទីរ អង្គភាពសាមីអំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

ក្នុងករណីដែលមន្ត្រីណាមួយក្នុងមុខតំណែងទាំងនេះ ត្រូវបានរកឃើញថា មានភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ ឬតាមតម្រូវនៃច្បាប់ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល និង ក្រុមប្រឹក្សារបស់ខ្លួន ត្រូវផ្តល់ការណែនាំដល់ប្រធានមន្ទីរ ឬ អង្គភាពសាមីដើម្បីលើកសំណើផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមកអភិបាលរាជធានី ខេត្ត។ ក្នុងករណីដែលប្រធានមន្ទីរឬអង្គភាពសាមីនោះពុំអនុវត្តតាមការណែនាំនេះទេ អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន អាចមានសិទ្ធិផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះដោយពុំចាំបាច់មានសំណើពីប្រធានមន្ទីរឬអង្គភាពសាមីនោះឡើយ។

ជំហានទី៣៖

ក្រោយពីបានទទួលបានសំណើពីអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យនិងអនុម័តលើសំណើខាងលើតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

ជំហានទី៤៖

បន្ទាប់ពីបានទទួលការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងដែលបានស្នើសុំឬចាត់វិធានការណ៍ចាំបាច់នានាបន្ថែមទៀតផ្អែកទៅតាមសេចក្តីសម្រេចនិងយោបល់ណែនាំរបស់ក្រុមប្រឹក្សា។

ការសម្រេចយល់ព្រមឬមិនយល់ព្រមលើសំណើរបស់ប្រធានមន្ទីរឬអង្គភាព ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃនៃថ្ងៃធ្វើការងារ។

ជំហានទី៥៖

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការទៅក្រសួង ស្ថាប័នសាមី និង ក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្សនិងការងារក្របខ័ណ្ឌ ដោយត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**៩.៣. មុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ**

ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងចាប់ពីថ្នាក់ប្រធានការិយាល័យជំនាញឬថ្នាក់ប្រហាក់ប្រហែលចុះក្រោមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមជំហាននានាដូចខាងក្រោម៖

ជំហានទី១៖

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដើម្បីពិភាក្សានិងផ្តល់ជ្រើសរើសបេក្ខជនដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងខាងលើ។

កិច្ចប្រជុំនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ដែលបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី។ ក្នុងករណីចាំបាច់ អភិបាលក្រុង ស្រុក ខណ្ឌ អាចអញ្ជើញប្រធានមន្ទីរ ឬ អង្គភាព ឬការិយាល័យជំនាញសាមីឲ្យចូលរួមក្នុងកិច្ចប្រជុំនេះ។

ក្នុងការជ្រើសរើសបេក្ខជនដែលស្នើតែងតាំង ជាបឋមត្រូវផ្តោតលើបេក្ខជនដែលជាមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយផ្អែកលើលក្ខណសម្បត្តិនិងឧបនិស្ស័យសមស្របដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្របនេះទេ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីក្នុងការស្នើសុំផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័ន ឬពីមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

<u>ជំហានទី២៖</u>

បន្ទាប់ពីមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងនេះទៅប្រធានក្រុមប្រឹក្សា ដើម្បីសុំការពិនិត្យនិងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

<u>ជំហានទី៣៖</u>

ក្រោយពីបានទទួលបានសំណើពីអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដើម្បីពិនិត្យនិងអនុម័តលើសំណើទាំងនោះ តាមនីតិវិធីដូចបានកំណត់ក្នុងចំណុចIVនៃសេចក្តីណែនាំនេះ។

<u>ជំហានទី៤៖</u>

បន្ទាប់ពីបានទទួលការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនទៅអភិបាលរាជធានី ខេត្ត តាមរយៈប្រធានមន្ទីរ អង្គភាពសាមី ដើម្បីចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងដែលបានស្នើសុំ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ ឬ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការចាំបាច់នានាបន្ថែមទៀតផ្អែកទៅតាមសេចក្តីសម្រេចនិងយោបល់ណែនាំរបស់ក្រុមប្រឹក្សាខ្លួន។ ប្រធានមន្ទីរ អង្គភាពសាមី ត្រូវពិនិត្យនិងផ្តល់យោបល់លើសំណើនេះជូនអភិបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសំណើនោះ។

<u>ជំហានទី៥៖</u>

ផ្អែកលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ និង មតិយោបល់របស់ប្រធានមន្ទីរ អង្គភាពសាមី អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យនិងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈ

អភិបាលរបស់ខ្លួនដើម្បីចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះឬអាចចាត់ឲ្យមានការស៊ើបអង្កេតចំពោះមូលហេតុដែលស្នើឲ្យមានការតែងតាំង ការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចនេះ។

ក្នុងករណីស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាល ត្រូវធ្វើលិខិតជម្រាបជូនអភិបាលក្រុង ស្រុក ខណ្ឌសាមី អំពីការមិនគាំទ្រចំពោះសំណើសុំតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។

<u>ជំហានទី៦៖</u>

បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីខាងលើ អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីនោះក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការទៅក្រសួង ស្ថាប័នសាមី និង ក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្សនិងការងារក្របខ័ណ្ឌ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារដូចមានកំណត់នៅក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ។

គោលការណ៍នៃការពិនិត្យនីត្យានុកូលភាពមានកំណត់នៅក្នុងចំណុចVនៃសេចក្តីណែនាំនេះ។

**ខ.៤. ការតែងតាំង ការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចមន្ត្រីរាជការនៃអង្គភាពរបស់ក្រសួង ស្ថាប័ន ដែលមានមុខងារផ្តល់សេវាគ្របដណ្តប់លើវិសាលភាពដែនដីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើសពីមួយ**

ចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៃអង្គភាពរបស់ក្រសួង ស្ថាប័នដែលមានមុខងារផ្តល់សេវាគ្របដណ្តប់លើវិសាលភាពដែនដីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើសពីមួយ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលអង្គភាពនោះមានការិយាល័យតាំងនៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួននិងប្រធានអង្គភាពសាមី ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់ចំណុច ខ.១ ខ.២ និងខ.៣ ដោយមានការពិគ្រោះយោបល់ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលពាក់ព័ន្ធ។

## III. សំណុំឯកសារសម្រាប់ការតែងតាំងការផ្លាស់ប្តូរនិងការបញ្ចប់ភារកិច្ចមន្ត្រី

ក្នុងដំណើរការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឲ្យមានភ្ជាប់មកជាមួយនូវសំណុំឯកសារចាំបាច់នានាសម្រាប់ធ្វើមូលដ្ឋានក្នុងការពិភាក្សាវាយតម្លៃ និងពិនិត្យសម្រេច។

សំណុំឯកសារទាំងនោះ ត្រូវរៀបចំតាមជំហានដោយឡែកៗពីគ្នាសម្រាប់ដាក់ជូនគណៈអភិបាល ក្រុមប្រឹក្សា និងក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានការកំណត់ខាងក្រោម៖

ក. សំណុំឯកសារសម្រាប់ដាក់ជូនគណៈអភិបាលរួមមាន៖

- លិខិតស្នើសុំរបស់នាយករដ្ឋបាល
- កំណត់ហេតុកិច្ចប្រជុំពិគ្រោះពិភាក្សារបស់នាយករដ្ឋបាលនិងថ្នាក់ដឹកនាំអង្គភាព
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)
- ឯកសារនានាពាក់ព័ន្ធសាមីខ្លួនដូចជាវិញ្ញាបនបត្រ សញ្ញាប័ត្រជំនាញ លិខិតឯកទេសពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ...។ល។

ខ. សំណុំឯកសារសម្រាប់ដាក់ជូនក្រុមប្រឹក្សារួមមាន៖

- លិខិតស្នើសុំរបស់អភិបាល
- កំណត់ហេតុកិច្ចប្រជុំពិគ្រោះពិភាក្សារបស់គណៈអភិបាល
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)
- ឯកសារនានាពាក់ព័ន្ធសាមីខ្លួនដូចជាវិញ្ញាបនបត្រ សញ្ញាប័ត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ....។ល។

គ. សំណុំឯកសារសម្រាប់ភ្ជាប់ជាមួយសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌដាក់ជូនអភិបាលរាជធានី ខេត្តរួមមាន៖

- លិខិតស្នើសុំរបស់អភិបាលក្រុង ស្រុក ខណ្ឌ
- កំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)
- ឯកសារនានាពាក់ព័ន្ធសាមីខ្លួនដូចជាវិញ្ញាបនបត្រ សញ្ញាប័ត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ....។ល។

ឃ. សំណុំឯកសារសម្រាប់ភ្ជាប់ជាមួយសំណើរបស់ប្រធានមន្ទីរ អង្គភាពជំនាញដាក់ជូនអភិបាលរាជធានី ខេត្តរួមមាន៖

- លិខិតស្នើសុំរបស់ប្រធានមន្ទីរ អង្គភាព
- កំណត់ហេតុកិច្ចប្រជុំថ្នាក់ដឹកនាំមន្ទីរ អង្គភាព
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)
- ឯកសារនានាពាក់ព័ន្ធសាមីខ្លួនដូចជាវិញ្ញាបនបត្រ សញ្ញាប័ត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ....។ល។

ង. សំណុំឯកសារសម្រាប់ភ្ជាប់ជាមួយសំណើរបស់អភិបាលរាជធានី ខេត្តផ្ញើជូនក្រសួង ស្ថាប័ន រួមមាន៖

- លិខិតស្នើសុំរបស់អភិបាលរាជធានី ខេត្ត
- កំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងករណីស្នើសុំតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមុខតំណែងប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)
- ឯកសារនានាពាក់ព័ន្ធសាមីខ្លួនដូចជាវិញ្ញាបនបត្រ សញ្ញាប័ត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ចុងក្រោយ...។ល។

ច. សំណុំឯកសារសម្រាប់ផ្ញើជូនក្រសួង ស្ថាប័នបន្ទាប់ពីចេញដីកា រួមមាន៖

- ដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- កំណត់ហេតុកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របាយការណ៍ស្តីពីកិច្ចដំណើរការនៃតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច
- បញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវបានតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន (សម្រាប់ការតែងតាំងឬការផ្លាស់ប្តូរ)

IV. **កិច្ចប្រជុំគណៈអភិបាលនិងកិច្ចប្រជុំក្រុមប្រឹក្សា**

រាល់កិច្ចប្រជុំរបស់គណៈអភិបាល និង កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដើម្បីពិភាក្សា និង/ឬ អនុម័តលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាសម្ងាត់ ដោយមិនអនុញ្ញាតឱ្យសាធារណជននិងសាមីខ្លួនចូលរួមឡើយ លើកលែងតែមន្ត្រី បុគ្គលិកដែលមានភារកិច្ចចាំបាច់ពាក់ព័ន្ធការសម្របសម្រួលនិងរៀបចំដំណើរការកិច្ចប្រជុំនេះប៉ុណ្ណោះ។

ក. កិច្ចប្រជុំគណៈអភិបាល

គណៈអភិបាល ត្រូវពិភាក្សាឲ្យមានការឯកភាពគ្នាលើសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីដែលបានស្នើឡើង។ ក្នុងការពិនិត្យពិភាក្សានេះ ត្រូវផ្អែកទៅលើលក្ខណសម្បត្តិនិងឧបនិស្ស័យដែលបានកំណត់សម្រាប់មុខតំណែងនីមួយៗដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះនិងមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរឬបញ្ចប់ភារកិច្ចមន្ត្រីដែលស្នើឡើង។

ខ. កិច្ចប្រជុំក្រុមប្រឹក្សា

ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា អភិបាលឬតំណាងរបស់គណៈអភិបាល ត្រូវធ្វើសេចក្តីរាយការណ៍ដោយបញ្ជាក់អំពីតម្រូវការនិងមូលហេតុជាក់លាក់នៃការស្នើសុំតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យនិងអនុម័ត។

ក្រុមប្រឹក្សា ត្រូវអនុម័តលើសំណើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី តាមរយៈការបោះឆ្នោតជាសម្ងាត់ដោយយល់ព្រម ឬ មិនយល់ព្រមទៅលើបេក្ខជនម្នាក់ៗដែលបានស្នើឡើង ដោយត្រូវផ្អែកទៅលើលក្ខណសម្បត្តិ និង ឧបនិស្ស័យស្របតាមមុខតំណែងនីមួយៗ និង មូលហេតុត្រឹមត្រូវដែលនាំឲ្យមានការផ្លាស់ប្តូរនិងបញ្ចប់ភារកិច្ចមន្ត្រីទាំងនោះ។

បន្ទាប់ពីសេចក្តីរាយការណ៍របស់អភិបាលឬតំណាងគណៈអភិបាល ក្រុមប្រឹក្សា អាចស្នើសុំឲ្យមានការពន្យល់បកស្រាយបំភ្លឺបន្ថែមអំពីមូលហេតុជាក់លាក់ផ្សេងទៀត ដើម្បីឲ្យមានមូលដ្ឋានច្បាស់លាស់មុននឹងធ្វើការបោះឆ្នោតយល់ព្រម ឬ មិនយល់ព្រមរបស់ខ្លួនទៅលើបេក្ខជនម្នាក់ៗដែលស្នើឡើងនោះ។

រាល់ការអនុម័តទៅលើសំណើសុំតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងណាមួយដែលចាត់ទុកថាបានការ លុះត្រាតែមានសម្លេងយល់ព្រមលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។ ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព។

ក្នុងករណីក្រុមប្រឹក្សាមិនអាចរកសម្លេងអនុម័តយល់ព្រមតាមការកំណត់ខាងលើ ក្រុមប្រឹក្សាត្រូវផ្តល់អនុសាសន៍និងស្នើឱ្យគណៈអភិបាលពិនិត្យវាយតម្លៃនិងផ្លាស់ប្តូរបេក្ខជននិង/ឬស្នើឱ្យសម្របសម្រួលឡើងវិញនូវរាល់ដំណើរការតែងតាំង ផ្លាស់ប្តូរ ដើម្បីរៀបចំសំណើដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តជាថ្មីឡើងវិញ។

ចំពោះការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រីនៅថ្នាក់រាជធានី ខេត្ត ប្រសិនបើនៅតែមិនអាចរកសម្លេងគាំទ្របាននៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកទី២ទៀតនោះ អភិបាលរាជធានី ខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍និងស្នើសុំគោលការណ៍ពិនិត្យសម្រេចពីក្រសួងមហាផ្ទៃនិង/ឬក្រសួង ស្ថាប័នសាមីជាបន្ទាន់។

ចំពោះការតែងតាំង ការផ្លាស់ប្តូរ ការបញ្ចប់ភារកិច្ចមន្ត្រីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រសិនបើនៅតែមិនអាចរកសម្លេងគាំទ្របាននៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាលើកទី២ទៀតនោះ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើសេចក្តីរាយការណ៍និងស្នើសុំគោលការណ៍ពីអភិបាលរាជធានី ខេត្តសាមីជាបន្ទាន់ ដើម្បីពិនិត្យនិងសម្រេច។

រាល់កំណត់ហេតុកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកិច្ចប្រជុំសម្ងាត់ខាងលើមិនត្រូវផ្សព្វផ្សាយជាសាធារណៈឡើយ។ ករណីចាំបាច់ខ្លឹមសារលម្អិតនៃរបៀបវារៈប្រជុំពាក់ព័ន្ធនឹងបញ្ហាសម្ងាត់នោះត្រូវកត់ត្រាដោយឡែកនិងត្រូវផ្សព្វផ្សាយឱ្យតែសមាជិកក្រុមប្រឹក្សាប៉ុណ្ណោះ។ ក្រុមប្រឹក្សា អាចអនុញ្ញាតឱ្យដកស្រង់ខ្លឹមសារគោលនៃកិច្ចប្រជុំនោះសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលឡើយ។

ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីពាក់ព័ន្ធនានា ត្រូវថែរក្សាឯកសារនានាពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួន កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលត្រូវបានស្នើតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ជាឯកសារសម្ងាត់និងមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈឡើយ។

## V. ការត្រួតពិនិត្យនីត្យានុកូលភាពដីការបស់អភិបាលរាជធានី ខេត្ត

អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងភ្ជាប់មកជាមួយនូវសំណុំលិខិតដូចមានកំណត់ក្នុងចំណុចIIIនៃសេចក្តីណែនាំនេះ មកក្រសួង ស្ថាប័នសាមីនិងក្រសួងមុខងារសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ដើម្បីពិនិត្យនីត្យានុកូលភាពនិងបំពេញបែបបទពាក់ព័ន្ធនឹងការរៀបបៀវត្ស ការងារក្របខ័ណ្ឌ និងការធានាការអនុវត្តតាមនីតិវិធីជាធរមាន។

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចត្រួតពិនិត្យនីត្យានុកូលភាពលើដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីដែលបំពេញការងារនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័នសាមីនីមួយៗ មានសមត្ថកិច្ចត្រួតពិនិត្យនីត្យានុកូលភាពលើដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីដែលបំពេញការងារនៅតាមមន្ទីរ អង្គភាព និងការិយាល័យជំនាញរបស់ខ្លួន។

ក្នុងករណីដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចណាមួយមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន ក្រសួង ស្ថាប័ន មានសមត្ថកិច្ចត្រួតពិនិត្យនីត្យានុកូលភាព ត្រូវធ្វើការឆ្លើយតបទៅរដ្ឋបាលថ្នាក់ក្រោមជាតិវិញយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច។

ក្រសួងមុខងារសាធារណៈ មានសមត្ថកិច្ចពិនិត្យ និង រៀបចំបំពេញបែបបទពាក់ព័ន្ធនឹងការរៀបចំបៀវត្សនិងការងារក្របខ័ណ្ឌ។

ក្នុងការត្រួតពិនិត្យនីត្យានុកូលភាព ប្រសិនបើពិនិត្យឃើញថា ការតែងតាំង ឬការផ្លាស់ប្តូរ ឬការបញ្ចប់ភារកិច្ចនេះធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន ក្រសួង ស្ថាប័នសាមីត្រូវធ្វើលិខិតណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះឱ្យធ្វើការពិនិត្យនិងកែតម្រូវឱ្យបានត្រឹមត្រូវឡើងវិញ។ ក្នុងករណីរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនបានធ្វើការកែតម្រូវទេនោះ ក្រសួង ស្ថាប័នសាមី ត្រូវធ្វើអន្តរាគមន៍ដោយចេញប្រកាសលុបចោលដីកាដែលធ្វើឡើងមិនត្រឹមត្រូវតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមានជាបន្ទាន់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានី ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ក្រុមប្រឹក្សានិងគណៈអភិបាលខណ្ឌ និងមន្ទីរ អង្គភាពជំនាញនានា ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

***កន្លែងទទួល៖***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *លេខាធិការដ្ឋានគ.ជ.អ.ប*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

## លក្ខណសម្បត្តិនិងឧបនិស្ស័យតាមមុខតំណែងនីមួយៗ

<table>
<tr><th>ឧបនិស្ស័យមុខតំណែង</th><th>ក្របខ័ណ្ឌ ឋានន្តរស័ក្តិ</th><th>លក្ខណសម្បត្តិ</th></tr>
<tr><td colspan="3">រាជធានី ខេត្ត</td></tr>
<tr><td>- នាយករងរដ្ឋបាលសាលារាជធានី ខេត្ត<br>- នាយកទីចាត់សាលារាជធានី ខេត្ត</td><td rowspan="2">- នាយក្រមការ</td><td>- មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីភាពល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។</td></tr>
<tr><td>- ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត</td><td>- មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររងផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុ<br>- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ<br>- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- មានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។</td></tr>
</table>

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| | រាជធានី ខេត្ត | |
| - នាយករងទីចាត់ការសាលារាជធានី ខេត្ត<br>- អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត<br>- ប្រធានការិយាល័យសាលារាជធានី ខេត្ត | - ក្រមការដើមខ្សែ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីភាពល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- - មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យសាលារាជធានី ខេត្ត | - ក្រមការ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការចាត់ចែងការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| | ក្រុង ស្រុក ខណ្ឌ | |
| - នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ- -ប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | - ក្រុមការ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - ប្រធានអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ | | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររងផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុ<br>- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ<br>- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- មានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ<br>- អនុប្រធានអង្គភាពលទ្ធកម្មក្រុងស្រុកខណ្ឌ | - នាយលេខាធិការរដ្ឋបាល | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
| --- | --- | --- |
| **មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត** | | |
| - ប្រធានមន្ទីរ អង្គភាព | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទក | - មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានមន្ទីរ អង្គភាព | - ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - ប្រធានការិយាល័យ | - ឋានន្តរស័ក្តិទី២នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យ | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| ការិយាល័យ អង្គភាពជំនាញក្រុង ស្រុក ខណ្ឌ | | |
| - ប្រធានការិយាល័យ អង្គភាព | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យ អង្គភាព | - ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ គ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |